ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សារណៈយោគយល់

រវាង

## លេខាធិការដ្ឋាន គ.ជ.អ.ប

ជាមួយនិង

## អង្គការអុកស្វាមនៅកម្ពុជា

ស្តីពី

## ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**អនុស្សារណៈយោគយល់**

**រវាង**

**លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**(គ.ជ.អ.ប)**

**និង**

# អង្គការអុកស្វាមនៅកម្ពុជា

## ស្តីពី

## ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

### ប្រការ១÷ គណនេយ្យភាពសង្គម

ផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី ១ (ឆ្នាំ២០១៦-២០១៨) និងដំណាក់កាលទី ២ (ឆ្នាំ២០១៩-២០២៣) ត្រូវបានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និតរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងបណ្តាអង្គការសង្គមស៊ីវិលពាក់ព័ន្ធក្រោមក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការងារគណនេយ្យភាពសង្គមគឺជាផ្នែកមួយដ៏សំខាន់នៃអភិបាលកិច្ច និងជាដំណើរការនៃការចូលរួមប្រកបដោយការស្តាបនារវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ និងអនុវត្តសកម្មភាពនានា។ សកម្មភាពទាំងនោះរួមបញ្ចូលនូវសកម្មភាពដែលប្រជាពលរដ្ឋ និងតំណាងប្រជាពលរដ្ឋ អាចធ្វើការផ្តល់យោបល់ត្រឡប់សម្រាប់ឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន និងអាចចូលរួមតាមដាន ត្រួតពិនិត្យ អំពីការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា មន្ត្រី និងអ្នកផ្តល់សេវាតាមរយៈ សេវារដ្ឋបាលឃុំ សេវាអប់រំ (បឋមសិក្សា) សេវាសុខាភិបាល (មណ្ឌលសុខភាព) សេវារដ្ឋបាលក្រុង ស្រុក ក៏ដូចជាសេវាមួយចំនួនផ្សេងទៀត ។

### ប្រការ២÷ គោលបំណងនៃអនុស្សារណៈយោគយល់

អនុស្សារណៈយោគយល់នេះមានគោលបំណងកំណត់អំពីការទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការរបស់ភាគីពីរគឺ លេខាធិការដ្ឋាន គ.ជ.អ.ប និង អង្គការអុកស្វាមនៅកម្ពុជា សម្រាប់ការអនុវត្តសកម្មភាពផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផ.អ.គ.ស) នៅក្នុងតំបន់គោលដៅ (ដូចមានក្នុងឧបសម្ព័នទី១) ។ អនុស្សារណៈនេះនឹងមានសុពលភាព ចាប់ពីថ្ងៃចុះហត្ថលេខាដល់ដំណាច់ឆ្នាំ ២០២១។ អង្គការអុកស្វាមនៅកម្ពុជា រំពឹងថានឹងមានតំបន់គោលដៅថ្មីបន្ថែមទៀត ចាប់ពីដើមឆ្នាំ ២០១៩ តទៅបន្ទាប់ពីព័ត៌មានស្តីពីហិរញ្ញប្បទានត្រូវបានកំណត់ច្បាស់លាស់។

**ប្រការ៣៖ ការទទួលខុសត្រូវរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**

**លេខាធិការដ្ឋានគ.ជ.អ.បព្រមព្រៀងដូចខាងក្រោម៖**

១. ផ្តល់ការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅ ស្តីពីខ្លឹមសារនៃ អនុស្សារណៈនេះ។

២. ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីជំនាញសុខាភិបាល មន្ត្រីជំនាញវិស័យអប់រំ (និងក្នុងវិស័យផ្សេងទៀត តាមការកំណត់ជាក់ស្តែង) នៅក្នុងតំបន់គោលដៅ ទាក់ទងនឹងទស្សនៈទាន ឧបករណ៍ ដំណើរការនៃការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម ពិសេសគោលការណ៍អភិបាលកិច្ច និងខ្សែគណនេយ្យភាព ព្រមទាំងតួនាទីភារកិច្ចរបស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិលដែលចុះកិច្ចសន្យាអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម និងអង្គការសង្គមស៊ីវិល(CSO) ដែលបានទទួលកិច្ចសន្យាពីអង្គការមិនមែនរដ្ឋាភិបាលក្នុងការលើកកម្ពស់គោលការណ៍ខាងលើ និងគាំទ្រសម្របសម្រួលការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុង តំបន់គោលដៅ។

៣. គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅតំបន់គោលដៅ ដោយប្រើផ្ទាំងរូបភាពធំ នៃកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និងសៀវភៅណែនាំអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋដោយមានការណែនាំបច្ចេកទេស ឬតម្រង់ទិសពីរបៀបនៃការផលិតព័ត៌មាន ការដាក់តាំងបង្ហាញការផ្សព្វផ្សាយ និងរបៀបនៃការប្រើប្រាស់ព័ត៌មានទាំងនេះក្នុងដំណើរការ ផ.អ.គ.ស។

៤. សហការបណ្តុះបណ្តាលតម្រង់ទិស (ផ្នែកផ្គត់ផ្គង់) ដល់មន្ត្រីបង្គោលរបស់អង្គការដៃគូអនុវត្ត(NGOs) ស្តីពីផែនការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីអោយមានភាពស្របគ្នាជាមួយនឹងវគ្គបណ្តុះបណ្តាលបន្តរបស់ផ្នែកតម្រូវការដល់ដៃគូតាមបណ្តាស្រុកគោលដៅ។

៥. ត្រួតពិនិត្យការអនុវត្តជាប្រចាំនូវការបំពេញការងារ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីជំនាញផ្នែកសុខាភិបាល អប់រំ (និងវិស័យផ្សេងទៀត តាមការកំណត់ជាក់ស្តែង) ដែលពាក់ព័ន្ធ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងដំណើរការដាក់ពិន្ទុដោយផ្នែកទាំងពីរ (អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ) ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវ ពេញលេញ និងស្របតាមឯកសារផែនការអនុវត្តការងារគណនេយ្យភាពសង្គម។

៦. រៀបចំ និងចែករំលែកនូវរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តជាទៀងទាត់ ដូចដែលបានឯកភាពគ្នាតាមមាតិកា នៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី ២។

៧. សហការជាមួយអង្គការអុកស្វាមនៅកម្ពុជា ក្នុងការកំណត់ចំណុចទាក់ទងគ្នារវាង ផ.អ.គ.ស និងតួនាទីការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ក្រុង និងខណ្ឌ និងក្នុងការពង្រីក ផ.អ.គ.ស ទៅដល់កម្រិតស្រុក។

៨. ផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីអង្គការអុកស្វាមនៅក្នុងការអនុវត្តសកម្មភាពខាងផ្នែកផ្គត់ផ្គង់ នៃផ.អ.គ.ស ។

១០. សហការជាមួយអង្គការអុកស្វាមក្នុងការលើកកម្ពស់ការយល់ដឹង និងការចូលរួមពីសាធារណៈជន នៅក្នុងការអនុវត្តសកម្មភាព ផ.អ.គ.ស។

**ប្រការ៤÷ ការទទួលខុសត្រូវរបស់អង្គការអុកស្វាម**

អង្គការអុកស្វាមនៅកម្ពុជា បានព្រមព្រៀងដូចខាងក្រោម៖

១. ផ្តល់ការណែនាំដល់បុគ្គលិក និងអង្គការសង្គមស៊ីវិលដៃគូអនុវត្តរបស់ខ្លួនទាក់ទងនឹងខ្លឹមសារនៃអនុស្សារណៈនេះ។

២. ធានាថាការបណ្តុះបណ្តាល ត្រូវបានផ្តល់ដល់អង្គការសង្គមស៊ីវិលដែលជាដៃគូអនុវត្តរបស់ខ្លួន អំពីទស្សនទាន ឧបករណ៍ នីតិវិធី ដំណើរការ គោលការណ៍អភិបាលកិច្ចល្អ ខ្សែគណនេយ្យភាព សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការអនុវត្ត ផ.អ.គ.ស។

៣. ផ្តល់ថវិកាគាំទ្រឱ្យទាន់ពេលវេលាដល់អង្គការសង្គមស៊ីវិលដែលជាដៃគូរបស់ខ្លួន ដើម្បីគាំទ្រការអនុវត្តសកម្មភាពផ្នែកតម្រូវការ ដែលនៅក្រោមការទទួលខុសត្រូវរបស់អង្គការដៃគូនោះ។

៤. ត្រួតពិនិត្យការអនុវត្តជាប្រចាំរបស់ខ្លួន ឬអង្គការសង្គមស៊ីវិលដែលជាដៃគូ ដើម្បីធានាថា ផ.អ.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវ ពេញលេញ មានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមឯកសារផ.អ.គ.ស។

៥. រៀបចំ និងចែករំលែកនូវរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តជាទៀងទាត់ ដូចដែលបាន ឯកភាពគ្នាតាមមាតិកានៃរបាយការណ៍ ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី២។

៦. សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ធនធានរបស់ខ្លួនដើម្បីជួយគាំទ្រដល់ផ្នែកផ្គត់ផ្គង់ ស្របតាមកិច្ចព្រមព្រៀងជាក់លាក់ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការអុកស្វាម។ សកម្មភាពផ្នែកផ្គត់ផ្គង់ ដែលអង្គការអុកស្វាមអាចនឹងពិចារណាគាំទ្រ រួមមានដូចជា៖ ការបណ្តុះបណ្តាល ការរៀបចំព្រឹត្តិការណ៍ ការសិក្សាស្រាវជ្រាវ ការវិភាគទិន្នន័យ ការចងក្រងបទពិសោធន៍ល្អៗ និងសកម្មភាពផ្សេងៗទៀត ដែលនឹងពិភាក្សាបន្ថែម នៅដើមឆ្នាំ ២០១៩ ខាងមុខ។

៧. កំណត់ និងធ្វើសកម្មភាពលើចំណុចទាក់ទងគ្នារវាង ផ.អ.គ.ស និងតួនាទី ការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ក្រុង និងខណ្ឌ និងក្នុងការពង្រីក ផ.អ.គ.ស ទៅដល់កម្រិតស្រុក។

៨. កំណត់ និងធ្វើសកម្មភាពលើចំណុចទាក់ទងគ្នារវាង ផ.អ.គ.ស និងសេវាដែលទាក់ទងនឹងសុវត្ថិភាពសង្គម ដូចមានចែងក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសលើជនងាយរងគ្រោះនៅទីប្រជុំជន។

៩. សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការលើកកម្ពស់ការយល់ដឹង និងការចូលរួមពីសាធារណៈជន នៅក្នុងការអនុវត្តសកម្មភាព ផ.អ.គ.ស។

**ប្រការ៥÷ ការចាត់ចែងសម្របសម្រួល**

ក្នុងករណីចាំបាច់ ភាគីទាំង២ អាចរៀបចំកិច្ចប្រជុំសម្របសម្រួល លើការអនុវត្តគណនេយ្យភាពសង្គម ជាប្រចាំ ក្នុងគោលបំណងដូចខាងក្រោម៖

- ពិនិត្យមើលអំពីភាពរីកចម្រើន នៃការអនុវត្តការងារគណនេយ្យភាពសង្គម
- កំណត់ពីបញ្ហា និងស្វែងរកដំណោះស្រាយប្រកបដោយកិច្ចសហការគ្នា
- ពិភាក្សា និងព្រមព្រៀងលើចំណុចកែលម្អក្នុងដំណើរការអនុវត្តដែលបានលើកឡើងដើម្បីដាក់បញ្ចូលទៅក្នុងផែនការអនុវត្តនាពេលអនាគត ។
- រៀបចំយុទ្ធសាស្ត្រ និងផែនការដើម្បីដកថយ និងធានានិរន្តរភាព
- ការងារផ្សេងៗទៀតទាក់ទងនឹងការអនុវត្តផែនការគណនេយ្យភាពសង្គមជាទូទៅ

**ប្រការ៦÷ ការធ្វើវិសោធនកម្ម ឬការបញ្ចប់អនុស្សារណៈយោគយល់**

អនុស្សារណៈយោគយល់នេះ អាចនឹងត្រូវបានធ្វើវិសោធនកម្មនៅពេលណាមួយ ក្នុងករណីដែលមានការព្រមព្រៀងពីភាគីទាំងពីរ។ ការបញ្ចប់អនុស្សារណៈនេះនឹងតម្រូវអោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច៨ សប្តាហ៍មុន និងមានការព្រមព្រៀងពីភាគីទាំងពីរ ទៅលើវិធានការសមស្រប ដើម្បីធានាឱ្យមានការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅ បន្ទាប់ពីការបញ្ចប់អនុស្សារណៈនេះ។

| | លេខាធិការដ្ឋាន គ.ជ.អ.ប | អង្គការអុកស្វាមនៅកម្ពុជា |
|---|---|---|
| ហត្ថលេខា៖ | | |
| ឈ្មោះ៖ | ចាំង ចំរើន | លឹម សុលីន |
| មុខងារ៖ | ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប | នាយិកាប្រចាំប្រទេស |
| កាលបរិច្ឆេទ៖ | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ |

**ឧបសម្ព័ន្ធទី១៖**

**តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៩ - ២០២១**

*តំបន់គោលដៅគ្រោងទុក (អង្គការដៃគូ នឹងត្រូវកំណត់ពេលក្រោយ)*

| កូដGIS | ឈ្មោះខណ្ឌ | ចំនួនសង្កាត់ | | ចំនួនសាលាបឋមសិក្សា | | ចំនួនមណ្ឌលសុខភាព | |
|---|---|---|---|---|---|---|---|
| | | ផ្នែកផ្គត់ផ្គង់ | ផ្នែកតម្រូវការ | ផ្នែកផ្គត់ផ្គង់ | ផ្នែកតម្រូវការ | ផ្នែកផ្គត់ផ្គង់ | ផ្នែកតម្រូវការ |
| ១២ | រាជធានីភ្នំពេញ | | | | | | |
| ១២០៨ | សែនសុខ | ៣ | ៣ | គ្រប់សាលាបឋមសិក្សាក្នុងសង្កាត់ទាំង៣ | | គ្រប់មណ្ឌលសុខភាពក្នុងសង្កាត់ ទាំង៣ | |

*__បញ្ជាក់៖__*

១. តំបន់គោលដៅគ្រោងទុក អាចនឹងមានការផ្លាស់ប្តូរបើចាំបាច់ ដោយស្របតាមការឯកភាពរវាងភាគីទាំងពីរ

២. អង្គការអុកស្វាមនៅកម្ពុជា នឹងសុំយោបល់ពីលេខាធិការដ្ឋាន គ.ជ.អ.ប ទាក់ទងតំបន់គោលដៅបន្ថែម នៅពេលព័ត៌មានទាក់ទងនឹងហិរញ្ញប្បទានត្រូវបានកំណត់ សម្រាប់រយៈពេលដល់ឆ្នាំ២០២១។ ថវិកាគ្រោងសម្រាប់អនុវត្តមួយឆ្នាំៗ ដែលអង្គការអុកស្វាមអាចរំពឹងបានមានប្រមាណ USD ២០០,០០០ (ពីររយពាន់ដុល្លារ)។ ថវិកានេះនឹងមានការកើនឡើងអាស្រ័យទៅតាមតំបន់គោលដៅដែលនឹងត្រូវពង្រីកបន្ថែម។

## ឧបសម្ព័ន្ធទី២÷ ទម្រង់មាតិកានៃរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម

១. សេចក្តីផ្តើម

២. វឌ្ឍនៈភាពនៃការអនុវត្ត

៣. បញ្ហាប្រឈម

៤ ស្ថានភាពហិរញ្ញវត្ថុ

៥. សេចក្តីសន្និដ្ឋាន